# ស្ត្រីជួបជុំគ្នា

លំនាំបទៈ  អារ៉ាប់ពីយ៉ា

១. សិទ្ធិស្ត្រីគឺជាសិទ្ធិមនុស្ស    ស្មើគ្នាស្រីប្រុសមានជីវិតគឺមានតំលៃ
សេចក្តីថ្លៃថ្នូរមិនថាមានឋានៈអ្វី    មានឬក្រក្រីមានតំលៃដូចៗគ្នា  មែនហើយ!

បន្ទរៈ អារ៉ាប់ពីយ៉ាៗ  សិទ្ធិស្ត្រី    អារ៉ាប់ពីយ៉ាៗ  យើងជួបជុំគ្នា
អារ៉ាប់ពីយ៉ាៗយើងសាមគ្គីគ្នា    យើងវិំពុះពារ  ហ៊ានទាមទារសិទ្ធិយើង  មែនហើយ!

២. យើងជាអ្វីជាស្ត្រីដូចៗគ្នា    យើងច្រៀងរួមគ្នាបង្ហាញពីសាមគ្គីពួតដៃ
យើងក្រោកឈរឡើងហ៊ាននិយាយមិនស្ងៀមអោបដៃ    ទាមទារសេរីសិទ្ធិយើងដែលត្រូវមាន  មែនហើយ!

បន្ទរៈ អារ៉ាប់ពីយ៉ាៗ  សិទ្ធិស្ត្រី    អារ៉ាប់ពីយ៉ាៗ  យើងជួបជុំគ្នា
អារ៉ាប់ពីយ៉ាៗ  យើងសាមគ្គីគ្នា    យើងវិំពុះពារហ៊ានទាមទារសិទ្ធិយើង  មែនហើយ !

៣. យើងរីករាយព្រោះយើងបានជួបជុំគ្នា    យើងបានយល់គ្នាក្នុងនាមយើងដែលជាស្ត្រី
ទោះមានឬក្រមានកិច្ចការឬមុខរបរអ្វី    យើងជាស្ត្រីយើងជួយគ្នាលើកស្ទួយសិទ្ធិយើងមែនហើយ !

បន្ទរៈ អារ៉ាប់ពីយ៉ាៗ  សិទ្ធិស្ត្រី    អារ៉ាប់ពីយ៉ាៗ  យើងជួបជុំគ្នា
អារ៉ាប់ពីយ៉ាៗ  យើងសាមគ្គីគ្នា    យើងវិំពុះពារ  ហ៊ានទាមទារសិទ្ធិយើង  មែនហើយ!

៤. យើងជួបគ្នារួមគ្នាចិត្តតែមួយ    នាំគ្នាលើកស្ទួយសិទ្ធិស្ត្រីឱ្យបានប្រពៃ
ស្មើនឹងបុរសមានជីវិតដែលល្អថ្លាថ្លៃ    មានសិទ្ធិសេរីស្មើៗគ្នាគ្រប់ជាតិសាសន៍  មែនហើយ!